# ការសំភាស៍របស់អ៊ុំស្រី អ៊ុក យ៉ុន

កៈ អ្នកធ្វើការសំភាស៍មានឈ្មោះសួន សុខលី ខៈ អ្នកត្រូវគេសំភាស៍ឈ្មោះ អ៊ុក យ៉ុន

**<u>ការសង្ខេបរបស់អ៊ុំស្រី អ៊ុក យ៉ុន</u>**

អ៊ុំស្រី អ៊ុក យ៉ុន គាត់មានអាយុ ៦៧ឆ្នាំ។អ៊ុំស្រី អ៊ុក យ៉ុន មានភេទស្រី។អ៊ុំស្រី អ៊ុក យ៉ុន មានទីលំនៅនាពេលបច្ចុប្បន្ននៅ ភូមិ៤ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។អ៊ុំស្រី អ៊ុក យ៉ុន មានកូនចំនួន ៣នាក់។អ៊ុំស្រី អ៊ុក យ៉ុន បានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំដាច់ប៉ុលពតរួច ១៩៧៩។អ៊ុំស្រី អ៊ុក យ៉ុន មានប្តីចំនួន ១នាក់។

កៈ សូមជំរាបសួរអ៊ុំ
ជាដំបូងខ្ញុំថ្លែងអំណរគុណដល់អ៊ុំស្រីដែលអោយខ្ញុំធ្វើការសំភាស៍អំពីជីវប្រវិត្តរបស់អ៊ុំស្រី។ ហើយការសំភាស៍នេះធ្វើឡើងដោយសាលាដែលមានឈ្មោះថាសកលវិទ្យាល័យ BYU ដោយសារតែសកលវិទ្យាល័យនិងចង់ថែរក្សារជីវប្រវិត្តរបស់អ៊ុំស្រី ទុកអោយកូនចៅជំនាន់ក្រោយមើលនិងស្តាប់។ បន្ទាប់ពីការសំភាស៍នេះរួចហើយ តើខ្ញុំអាចសុំអ៊ុំស្រីដាក់ការសំភាស៍នេះនៅក្នុងប្រពន្ធ័វេបសាយមួយដែលមានឈ្មោះថា WWW. Cambodianoralhistories.byu.edu បានដែលឬទេអ៊ុំស្រី?

ខៈ ចារបាន។

កៈ ហើយខ្ញុំជាអ្នកសំភាស៍អំមានឈ្មោះថា សួន សុខលី ហើយការសំភាស៍នេះធ្វើឡើងនៅថ្ងៃទី ០៣ ខែ ០២ ឆ្នាំ២០១៨ ដែលមានទីតាំងនៅភូមិ០៤ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។ ចឹងសំនួរទីមួយខ្ញុំសូមសួរអ៊ុំស្រីថា តើអ៊ុំមានឈ្មោះនិងនាមត្រកូលអ្វីដែលអ៊ុំ?

ខៈ ចារខ្ញុំឈ្មោះ អ៊ុក យ៉ុន។

កៈ ហើយអ៊ុំមានឈ្មោះហៅក្រៅដែលទេអ៊ុំ?

ខៈ ហៅក្រៅគេហៅ តូច។

កៈ ចារសំបូរអ្នកឈ្មោះ តូច។

ខៈ ចាខ្ញុំជាកូនតូច កើតក្រោយគេនោះ ស្រី៣នាក់ ខ្ញុំនិងពៅគេហើយតូចជាងគេ ដល់ពេលនេះគេចេះតែហៅខ្ញុំតូចទៅ។

ក៖ ចារឈ្មោះតូចពិរោះណាស់អ៊ុំ។

ខ៖ ចារ។

ក៖ ខ្ញុំសុំសួរអ៊ុំថា អ៊ុំមានអាយុប៉ុន្មានហើយឆ្នាំនេះ?

ខ៖ ខ្ញុំ៦០ ទៅ៦៧អីនិងអូន។

ក៖ អ៊ុំ៦០ ទៅ៦៧ឆ្នាំ ចឹងអ៊ុំកើតនៅឆ្នាំណា ខែណាដែលអ៊ុំ?

ខ៖ អ៊ុំចាំតែឆ្នាំដែលអ៊ុំកើតនិង តែខែអត់ដឹងទេដូចជាភ្លេច។ អរខែដូចជាខែភត្របទ។

ក៖ ចាដល់ពេលឆ្នាំ?

ខ៖ ឆ្នាំថោះ។

ក៖ ហើយដល់ពេលឆ្នាំកំណើតអ៊ុំ ដូចជាឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានអ៊ុំចាំទេ?

ខ៖ អើ ១៩៦៣។

ក៖ ហើយសូមសួរអ៊ុំទៀតថាទីកន្លែងកំណើតកើតនៅឃុំអី ភូមិអី ស្រុកអីដែលអ៊ុំ?

ខ៖ ខ្ញុំកើតកំណើតនៅស្រុកល្វាអែម ខេត្តកណ្ដាល។

ក៖ ហើយសូមសួរទៀតថាអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែល?

ខ៖ ខ្ញុំមានបងប្អូន ៨ នាក់។

ក៖ ចាចឹងអធ្យាស្រ័យអ៊ុំអាចរៀបរាប់ឈ្មោះ បងប្អូនដែលអ៊ុំមានទាំង ៨ នាក់និងបានទេ?

ខ.ចាបានតាស ប៉ុនន្តែមានអ្នកស្លាប់ខ្លះហើយនិង។

ក៖ ចាអ៊ុំអាចនិយាយទាំងអ្នកស្លាប់ដែល។

ក៖ ចាអ្នកស្លាប់ឈ្មោះ អ៊ុកចាន់ទី ចាបានមក អ៊ុកឃី បងស្រីនិងណាពីរនាក់
នៅរស់ទេអ៊ុកឃីណា បានមកទៀត អ៊ុកកាននិងបងប្រុសខ្ញុំ ចារួចហើយបានមកខ្ញុំ អ៊ុកយ៉ុន
ដែលហៅថាតូចនិងណា ចាក៏បានបន្ទាប់ឈ្មោះ អ៊ុកឡៅ គាត់និងស្លាប់ហើយចា
រួចបានមក
អ៊ុកឡៃនិងក៏ស្លាប់ដែលគាត់ទៅធ្វើទារហ៊ានក៏ទៅជាន់មីនស្លាប់នៅនិងគេហៅគុកតាក្រៃ

ជ្រៃចំរៀង ហើយបានមក អ៊ុកលី នៅធ្វើស្រែចំការនៅជ្រួយដងហួសគៀនស្វាយយើងនិង ហើយបានមួយទៀត អ៊ុកបួន នៅបាត់ដំបងរាល់ថ្ងៃនិងណា។

កៈ ចាចឹងបានន័យថាស្លាប់បួន នៅរស់បួនមែនទេអ៊ុំ?

ខៈ ចា។

កៈ ចាចឹងអរគុណអ៊ុំ អ៊ុំនៅចាំច្បាស់ណាស់ ហាហា។

ខៈ ហើយចង់សួរអ៊ុំទៀតថា តើអ៊ុំជាកូនទីប៉ុន្មានដែលអ៊ុំ?

ខៈ ខ្ញុំកូនទីបួន។

កៈ ចាហើយអ៊ុំមានចង់ចាំសាច់រឿងអីខ្លះពេលដែលអ៊ុំនៅតូចៗ?

ខ. នៅតូចៗដូចថាឪពុកម្ដាយគាត់ទៅធ្វើស្រែចំការអីចឹងទៅណាអូន
ដល់នេះបងស្រីខ្ញុំគាត់ទៅរៀនទៅអីចឹងទៅ
ដល់ពេលមកផ្ទះវិញគាត់ដាំបាយដាំអីអោយខ្ញុំហូមចឹងណា ដឹងដែលអនុស្សាវរីបងស្រី
និងបងប្រុសអី
ចារួចហើយដល់ពេលខ្ញុំបានទៅរៀនចូលរៀនចូលអីឪពុកម្ដាយខ្ញុំគាត់ប្រើអោយមើលប្អូន
មើលអីខ្លះចឹង។

កៈ ចាហើយនៅពេលដែលអ៊ុំនៅពីក្មេងតើអ៊ុំចូលចិត្តធ្វើអីខ្លះអត់?
អ៊ុំពេលនៅក្មេងចូលចិត្តធ្វើអី?

ខ. អ៊ុំគ្មានចូលចិត្តធ្វើអីទេ ចូលចិត្តតែដូចថាពរប្អូន លួងប្អូនអីចឹងណា
ចាជួយការងារឪពុកម្ដាយគាត់ធ្វើស្រែចំការណា នៅមើលតែប្អូននិងអូន ចា។

កៈ ហើយអើខ្ញុំចង់សួរអ៊ុំទៀតថា
តើនៅពេលនេះពួកគាត់កំពង់តែរស់នៅកន្លែងណាខ្លះដែលអ៊ុំ?

ខៈ បងប្អូនអ៊ុំ បងប្អូនខ្ញុំនៅជ្រួយដងនិង មួយនាក់
ហើយនៅអន្លង់ក្ងានភ្លើងឆេះផ្ទះនិងទៅនៅខាងអន្លង់ក្ងាននិងមួយនាក់
ហើយមួយទៀតនៅ ហើយនិងប្អូនខ្ញុំនៅបាត់ដំបងនិង ហើយប្អូនខ្ញុំអាប្រុសពៅនិងណា
នៅបាត់ដំបងពីរនាក់ ហើយនិងខ្ញុំនៅនេះ។ បងប្អូននៅបែកគ្នាចឹងហើយមីអូនអើយ
បើស្រុកទេសយើងផ្ទះសំបែងឪពុកម្ដាយអីដូចថាកាលនិងយើងចេះតែមិនទាន់បានទៅចឹង

អើខាងអច្ចាធរនិងគេអោយតែមានអ្នកនៅនិងគេចេះតែវាស់ចែកៗ
ហើយយើងនេះវានៅឆ្ងាយណាយើងអត់បានវិញទេ
ដល់ចឹងទៅខ្ញុំអត់បានទៅនៅស្រុកវិញទេ ចា។

ក៖ អរគុណអ៊ុំ ចឹងខ្ញុំសូមសួរអ៊ុំទៀតថា តើម្ដាយនិងឪពុករបស់អ៊ុំមានឈ្មោះអីគេដែលអ៊ុំ?

ខ៖ ឪពុកខ្ញុំឈ្មោះ អ៊ុំកែវ ចំណែកម្ដាយខ្ញុំគាត់ឈ្មោះ សៀង តូ។

ក៖ ចាហើយចុះ ថ្ងៃខែឆ្នាំកំណើតពួកគាត់តើអ៊ុំចាំអត់ ឪពុកម្ដាយអ៊ុំណាស់?

ខ៖ អត់ចាំផងអូន ប៉ុន្តែដឹងតែម៉ែខ្ញុំឪពុកខ្ញុំគាត់ឆ្នាំរោង រួចម្ដាយខ្ញុំឆ្នាំរក។

ក៖ ចា។

ខ៖ ចាគាត់អាយុច្រើនហើយណាអូន។

ក៖ ចាហើយពួកគាត់រាល់ថ្ងៃស្លាប់អស់ហើយ?

ខ៖ ស្លាប់អស់ហើយអូន ស្លាប់នៅសម័យប៉ុលពត។

ក៖ ហើយចុះអ៊ុំអើដឹងថាពួកគាត់កើតនៅកន្លែងដែលទេអ៊ុំ?

ខ៖ ឪពុកខ្ញុំគាត់កើតនៅព្រៃវែង ម្ដាយខ្ញុំកើតនៅអើ ស្រុកល្វាអែមខេត្តកណ្ដាល។
ដល់គាត់បានម្ដាយខ្ញុំក៏គាត់នាំអើម្ដាយខ្ញុំនិងគាត់នៅល្វាអែមនិង
ឪពុកខ្ញុំក៏មកនៅជាមួយណា ហើយឪពុកខ្ញុំនិងគាត់កំព្រាតាំងពីតូចៗ គាត់អត់មានឪពុកទេ
គាត់នៅអត់មានឪពុកម្ដាយទេ គាត់នៅជាមួយឪពុកមៀគាត់។

ក៖ ចាហើយមួយទៀត
ខ្ញុំចង់សួរអ៊ុំថាតើឪពុករបស់អ៊ុំគាត់ធ្វើការងារអីសំរាប់ចិញ្ចឹមជីវិតរបស់គាត់ណាអ៊ុំ?

ខ៖ គាត់ធ្វើស្រែប្រាំង ស្រែអីនិងណា និងធ្វើចំការអីនិងចិញ្ចឹមកូនណា។

ក៖ ចាហើយផពុករបស់អ៊ុំគាត់គឺជាមនុស្សបែបណាដែលសំរាប់អ៊ុំ ដូចជាស្លូត
កាចអីចឹងណាអ៊ុំ?

ខ៖ គាត់មិនមែនជាង្នកកាចហើយក៏មិនមែនជាអ្នកស្លូតអីដែល
ហើយគាត់ក៏អត់ជាអ្នកហូមស្រាហូមអីដែល គាត់ដូចថាល្អណាស់ឪពុកខ្ញុំ។

កៈ ចាហើយចុះម្ដាយអ៊ុំវិញតើគាត់ធ្វើអីខ្លះសំរាប់ចិញ្ចឹមជីវិត ហើយនិងកូនៗដែលអ៊ុំ?

ខៈ ម្ដាយខ្ញុំគាត់ពីរនាក់ប្ដីប្រពន្ធគាត់និង
គាត់ធ្វើស្រែចំការនិងរួចហើយដូចថាគាត់មើលកូនមើលអីខ្លះនៅផ្ទះ ចា។

កៈ ហើយម្ដាយរបស់អ៊ុំគាត់គឺជាមនុស្សបែបណាដែលសំរាប់អ៊ុំ?

ខៈ ម្ដាយខ្ញុំគាត់ក៏ល្អដែល ម្ដាយខ្ញុំនោះចារ គាត់ដូចថាគាត់ខំប្រឹងរកលុយកាក
ប៉ះសណ្ដែកប៉ះអី ជ្រូតស្រូវអីដើម្បីកូន យកលុយ
យកស្រូវនិងសណ្ដែកនិងលក់ទៅដើម្បីបានលុយចិញ្ចឹមកូនណា គាត់មានកូនច្រើន
កូនដល់ទៅប្រាំបីរនាក់ឯនោះ។

កៈ ចាអរគុណអ៊ុំ។ ចឹងខ្ញុំសូមសួរអ៊ុំទៀតថា អ៊ុំចាំសាច់រឿងអីខ្លះអំពីរឪពុកម្ដាយរបស់អ៊ុំ
ពេលដែលអ៊ុំរស់នៅជាមួយគាត់ណា? ដូចជាគាត់បានធ្វើអីខ្លះសំរាប់កូនៗ
ដូចជារត់លេងឬក៏គាត់ធ្វើអីអ៊ុំ?

ខៈ គាត់ធ្វើអីដូចថាគាត់ឃើញកូនចឹងទៅ គាត់អាណិតស្រលាញ់កូនចឹងទៅណា
ចារពេលណាខែចូលឆ្នាំទៅគាត់ជួយរំលែកដូចថាមានលុយកាកអីទៅគាតើទិញខោរអាវ
អោយកូនស្លៀកពាក់ចឹងណាចារ អោយលុយអោយកាកអីកូនចាយវាយអីចឹងទៅ
មានតែប៉ុននិងអ្នកមានគុណគាត់ជួយយើងបានតែប៉ុននិងព្រោះគាត់អត់ដែលណា ចារ។

កៈ ចឹងអរគុណអ៊ុំ ហើយចុះអ៊ុំ ខ្ញុំសូមសួរទៀតថា
តើជីដូនជីតារបស់អ៊ុំខាងម្ដាយមានឈ្មោះអីគេដែលអ៊ុំចាំទេ?

ខៈ ជីដូនជីតា ជីតាខ្ញុំឈ្មោះអើ។

កៈ ខាងម្ដាយណាអ៊ុំ?

ខៈ ខាងម្ដាយគាត់ឈ្មោះអើ មើលខ្ញុំអត់ស្គាល់ត្រកូលគាត់ទេ ប៉ុន្ដែគាត់ឈ្មោះតាសៀង
យាយយឹម ចារ ប្រពន្ធគាត់ឈ្មោះយាយយឹម អើជីតាខ្ញុំឈ្មោះសៀង។

កៈ ហើយចុះខាងឪពុកវិញអ៊ុំ?

ខៈ ខាងឪពុកអើ ឈ្មោះតាអ៊ុក យាយយឹមដែល។

កៈ អ៊ុំអាចអង្គុយអោយស្រួលចុះ មិនអីទេ អង្គុយយ៉ាងមេចក៏បានដែលអ៊ុំ។

ខ៖ ចារអត់អីទេកូន ខ្ញុំឈឺ។

ក៖ អ៊ុំឈឺអី?

ខ៖ ខ្ញុំឈឺតែជើងមួយនិងកូន ឈឺដើរអត់ចង់រួចឯណា វាចេះតែឈឺក្នុងជើងនិងណាអូន ដូចគេថាយើងឈឺសន្លាក់អីមិនដឹងដែលណា ឈឺហើយពេលណាខ្ញុំដើររុញលៀសអីចឹងទៅបានអារទេសនិងទប់យើងដូចឈើច្រត់ចឹង បានដើរបានតិចៗទៅ កុំអីនិងដើរអត់រួចទេអូន។

ក៖ ចារអរគុណអ៊ុំ ហើយខ្ញុំចង់សួរអ៊ុំទៀតថា តើពួកគាត់កើតនៅក្នុងឆ្នាំណាអីអ៊ុំដឹងទេ? ជីដូនជីតាណា?

ខ៖ អរអត់ដឹងទេ អត់ចាំទេកូនអើយ អត់ដឹងទេ។

ក៖ ចាររួចចុះឆ្នាំខ្មែរអីអត់ដឹងដែលអ៊ុំ?

ខ៖ យាយខ្ញុំ ក៏មិនដឹងគាត់ឆ្នាំអី តាក៏មិនដឹងគាត់ឆ្នាំអី ដឹងតែម៉ែហើយនិងឪពុកខ្ញុំនិង។

ក៖ ចារហើយខ្ញុំសូមសួរអ៊ុំថា តើអ៊ុំបានដឹងសាច់រឿងអីពីរពួកគាត់អត់? ជីដូនជីតាអ៊ុំធ្លាប់ធ្វើអីចឹង?

ខ៖ គាត់ពីដើមមកតាខ្ញុំនិងគាត់ធ្វើមេស្រុក ដឹងតែប៉ុននិង ហើយដល់ពេលខ្ញុំធំទៅគាត់ក៏ឈប់ទៅព្រោះគាត់ចាស់ហើយ ចារ។

ក៖ ហើយសូមសួរអ៊ុំថា អ៊ុំកើតទាន់ជំនាន់ប៉ុលពតទេអ៊ុំ?

ខ៖ ពេញតែម្តងមីអូន សម័យប៉ុលពតនិងគេអោយអ៊ុំរែកដី រែកអីនិងជិតងាប់ហើយ ហាហា បើយើងខ្ជិលគេយកទៅវៃចោល ចារសម័យនិងចឹង។

ក៖ ចឹងខ្ញុំអាចអនុញ្ញាតអ៊ុំជួយរៀបរាប់ពីពេលវេលាដែលអ៊ុំបានឆ្លងគាត់នៅសម័យប៉ុលពតនិង តិចបានអត់អ៊ុំ ថាពិបាកអ្វីខ្លះធ្វើអីខ្លះនៅពេលនិងណាអ៊ុំ?

ខ៖ ពិបាកនោះវាសេនពិបាកហើយ ឪពុកមៀខ្ញុំគេយកទៅសំលាប់ចោលទាំងកូនគាត់ កូនបង្កើតទាំងកូនប្រសារ៣នាក់ឪពុកណា ចារមួយអន្លង់ ហើយឪពុកម្តាយ ឪពុកខ្ញុំសម័យប៉ុលពតនិងគាត់អត់ពេកអូន អត់ណាស់គាត់ឃ្លានណាស់

គាត់សុំសិល៍ហើយគាត់ឃើញចឹងចក់ណាអូនណា
គាត់ដើរអត់រួចទេតែគាត់វៃចឹងចក់និងយកមកធ្វើជាម្ហូប ខ្ញុំអត់ចង់រំលឹកទេរឿង។

ក៖ ចារអ៊ុំអាចនិយាយនូវអ្វីដែលអ៊ុំចង់និយាយ។

ខ៖
ខ្ញុំចង់និយាយថានឹកសម័យនុះឡើងគឺថាខ្ញុំអាណិតណែកបងប្អូនជីដូនជីតាខ្ញុំដែលគាត់វេទនា ដូចជាជីដូនខ្ញុំសម័យនិងគេអាបេចាក់ណា
រួចហើយមីងខ្ញុំពៅនិងគាត់សែងគាត់លីតែយាយខ្ញុំនិង
ដល់ពេលគាត់យាប់ពេកគាត់ស្លាប់សម័យយើងសង្គ្រាមនិងណា
កាលសម័យលុននុលនិងអត់បានឃើញមុខគាត់រហូតជីដូនមួយខ្ញុំនិងណា
ដល់តែមកឪពុកខ្ញុំម្ដាយខ្ញុំនេះ ម្ដាយបាននៅរហូតដល់យើងរំដោះហើយ
ខ្ញុំឃើញឪពុកខ្ញុំស្លាប់ដល់តែគាត់អត់ឃ្លានគ្មានអីហូម
ដូចថាគាត់មនុស្សប្រុសគាត់ត្រូវការហូមច្រើនណាកូន។ ចារឪពុកខ្ញុំអត់
ខ្ញុំឃើញឪពុកខ្ញុំអត់ចឹង ខ្ញុំអាណិតឪពុកខ្ញុំពេក
ខ្ញុំទៅខ្ញុំខ្លាចឈ្លើងទឹកបឹងនៅពោត៏សត្វនិងឈ្លើងច្រើនណាស់គ្រាន់តែយើងដើរចឹងទៅវាតោងហើយ ខ្ញុំខ្លាចណាស់ទៅជាភ្លីភ្លើអស់ហើយដូចថាយើងវាខ្លាចពេកណា
ខំយកឈៀ្បងទៅចត់ត្រី បានតែឈ្លើង ចុះយើងដើរទៅភ្លុង់ៗចឹងអត់បានត្រីបានអីទេ
ដល់ហើយខ្ញុំអត់អោយឪពុកខ្ញុំហូមទេ ដល់គាត់ឃ្លានពេកទៅឡើងស្លាប់អត់មានអីហូម
អត់មានជីវជាតិសោះ ហើមហើយរាកមូលទៀតនិងឪពុកខ្ញុំ។
ម្ដាយខ្ញុំដល់ពេលរំដោះនិងក៏គាត់ដើរអត់រួចដែលដល់ពេលហើយទៅខ្ញុំនិងប្អូនពៅសែងគាត់ សែងរួចហើយអូនអើយជើងខ្ញុំនិងបុកអាជីងជុង (ជុងឈើ) និងដើរអត់រួចទេ
ឡើងជាំជើងខ្ញុំដើរអត់រួច
ដល់ពេលបានមកដល់កន្លែងគេរំដោះលែងខ្លាចប៉ុលពតហើយណា
ខ្ញុំដើរអត់រួចទេខ្ញុំជាន់ជើងខ្ញុំ ហើយគេចេះតែតោះទៅមុខទៀត ទៅមុខទៀត
ខ្ញុំដើរអត់រួចទេទៅសុំរទេសគេជិះហើយម្ដាយខ្ញុំនិងឈើផង
គេអាណិតគេអោយអង្គុយជិះទៅ វាកំសត់ណាស់ កំសត់មែនទែន
រួចហើយពេលនិងបែកបងប្អូនខ្លះគេអោយទៅទន្លេ
ហើយយើងនៅឯសរហោករនិងរត់ណាអូន
រត់ចេញពីកន្លែងតំបន់ដែលយើងពិបាករស់នៅនិងណា

បើមិនចឹងទេវានាំយើងទៅវៃចោលហើយ ដល់ចឹងទៅក៏នាំគ្នារត់កាត់ព្រៃរនាម
អូនអើយរត់ទាំងយប់ទាំងថ្ងៃហើយដែលវាតាមមកទាន់អ្នកមិនចេះឆ្លើយវាវៃសំលាប់ភ្លាមៗ
និងបើអ្នកមិនចេះឆ្លើយណា។

កៈ ឆ្លើយអីគេអ៊ុំ?

ខៈ ឆ្លើយចេះ វាឈរសួរយើងថាចេះ ថាហ៊ានវៃសង្គ្រោះជាតិទេ
ដល់នេះភ័យខ្លាចពេកក៏អ្នកខ្លះឆ្លើយថាហ៊ាន ថាចឹងនិង ថាហ៊ាន
ដល់តែថាហ៊ានស្រាប់តែវាថាចឹង ហ៊ានវៃជាមួយ អើគេធ្វើសង្គ្រោះណា
ថាហ៊ានវៃប៉ុលពតទេថាហ៊ាន ពូនិងគាត់ថាហ៊ាន
ដល់ចឹងទៅក៏សួរថាឯណាបងប្អូនមិត្តឯងខ្លះ? បងប្អូនដែលទៅនិងគេអោយអង្គុយម្ដុំណា
ដល់ចឹងហើយក៏សួរថាអាឡូវនេះ នេះប៉ុលពតហ៊ានសំលាប់ប៉ុលពតទេ យើងជាប៉ុលពត
គេថាចឹងណា រួចខ្ញុំញ័អូនអើយខ្ញុំខ្លាចគេសួរចឹង
ហើយពូនិងគាត់ឆ្លើយចឹងគាត់អត់យល់ណា គាត់ឆ្លើយចឹងគេយកទៅវៃទាំងអស់
ទាំងអាតូចអាតាចអាកូនចៅមីងមាម្ដាយអីនិងគេសម្លាប់ចោលទាំងអស់គ្នានិង
រត់ទៅជាមួយខ្ញុំនិងហើយអ្នកដែលវាអត់បានសួរនិងចេះតែនៅរស់ដូចខ្ញុំ ដូចម្ដាយខ្ញុំអីនិង
វេទនាណា ហើយសួរខ្ញុំដែល សួរថាមិត្តឯងនិងមកយ៉ាងមេច ខ្ញុំមិនដឹងមកយ៉ាងមេចទេ
បើកំពង់តែបោកស្រូវគេហៅអោយចេញៗមក
ខ្ញុំចេះតែចេញតាមគេទៅខ្ញុំអត់ដឹងថាយ៉ាងមេចផង
ខ្ញុំឆ្លើយចឹងណាបានៗវាទុកជីវិតយើងរស់និងអូន
កុំអីងាប់ហើយវៃចោលខ្ទីចគ្មានសល់ទេសមួយនោះនិង តែប៉ុននិងកូន។

កៈ ចារអរគុណអ៊ុំ។ ចឹងខ្ញុំសូមសួរអ៊ុំថានៅពេលនិងអ៊ុំមានអាយុប៉ុន្មានដែលអ៊ុំ?

ខៈ អ៊ុំអាយុ២០ជាង និងមិនដឹងម្ភៃប៉ុន្មានទេ។

កៈ ហើយពេលនិងអ៊ុំអាយុម្ភៃរជានៅសម័យដែលអ៊ុំរស់នៅជំនាន់ប៉ុលពតនិងអ៊ុំ
គេប្រើអោយអ៊ុំធ្វើអីខ្លះដូចជាសែងដី ឬក៏ធ្វើអីទៀតអ៊ុំ?

ខៈ គេប្រើអោយអ៊ុំធ្វើចំការចឹងទៅ វែកទឹកស្រោចបន្លែរ
ដល់គេដល់ខែអោយទៅច្រូតយើងទៅច្រូត គេអោយទៅវែកដី ទៅវែកដី
ទៅឆ្ងាយណាស់កូនអត់បាននៅជុំម្ដាយទេ
អត់បានជុំម្ដាយខ្ញុំហើយឪពុកស្លាប់ក៏ខ្ញុំអត់បានឃើញមុខឪពុកដែលសម្មួយប៉ុលពតនិង

ណា ចារគេអោយខ្ញុំទៅនុះនៅភ្នំអីគេហៅក្បាលប្រហោះឯណានុះ នៅត្រលូហាលទិលនុះ
ហើយខ្ញុំនៅនេះស្រុកពោតិ៍សត្វនិង ហើយទៅតំបន់សុទ្ធតែគ្រុនចាញ់ណា
កន្លែងគ្រុនចាណាអូនដល់យប់ឡើងមានគេហៅប្រតែនិងហោះឡើងភ្លឺពេញជីវ
ហើយខ្ញុំខ្លាចខ្លារទៀត ខ្លាចណាស់ ពេលយប់ឡើងគេដុតភ្លឹង
អាសត្វខ្លារនិងវាឃើញគោវាចង់ចាប់គោ ជួនកាលស្មៀមៗគេថាប្រយ័ត្នៗខ្លេរៗ គេហៅខ្លេរ
គេអត់ហ៊ានហៅខ្លារទេ ខ្លេរៗប្រយ័ត្នខ្លេរ
និយាយពីថាភ័យអើយភ័យអូនអើយបន់ស្រន់ជីដូជីតាអស់ហើយអូនអើយ
ស្មានថាមិនបានមានជីវិតរស់ដល់ពេលនេះផង ណាអត់ឃ្លាន ណាហត់នឿយ
រួចហើយខ្ញុំអត់ចង់រស់ទេសម័យនិងគេថា កុំអោយហូមទឹកហូរពីលើមកអាទឹកក្រហមៗនិង
ខ្ញុំថាអើយផឹកទឹកនិងទៅហើយឆាប់ងាប់ទៅវេទនាណាស់ តែវាអត់ងាប់ ហាហា
មិនដឹងជាយ៉ាងមេចវាអត់ងាប់។ ប្អូនខ្ញុំគ្រុនចាញ់
គ្រុនចាញ់ហើយសន្លប់ហើយគេយកមកពេទ្យទាំងយប់
ពេទ្យអើបដិវត្តគេនិងណាគេយកមកពេទ្យនិងទាំងយប់ ចារ។

កៈ អរគុណអ៊ុំ។ ចឹងខ្ញុំសូមសួរអ៊ុំទៀតថា
តើអ៊ុំមានសាច់ញ្ញាតិដល់ទៃទៀតដែលរស់នៅប្រទេសក្រៅទេអ៊ុំ បងប្អូនអ៊ុំអីនិងមានទេ?

ខៈ សាច់ញ្ញាតិតែខាងសាច់ថ្លៃ ត្រូវជាប្រពន្ធពូខ្ញុំនិងតែអត់ដឹងទេ
គាត់ខឹងថាសម័យនោះអ្នកយកប្ដីគាត់ទៅវៃចោលអត់មានអ្នកឆ្ងាយទេ
គឺសាច់ញ្ញាតិរបស់ខាងពូខ្ញុំនិងណា គេបានធ្វើប្រធានភូមិអីនិង
គេយកឪពុកមាទៅវៃចោលប្អូនជីដូនមួយហើយនិងប្អូនសាច់ថ្លៃ
គេយកទៅវៃចោលមួយអន្លង់តែ៣នាក់និងទេ ឪពុក កូនប្រសារ និងកូនបង្កើត
ដល់ចឹងទៅពេលគាត់រួចពីសម័យនេះគាត់ គាត់ទៅគាត់មិនអោយដឹងព្រោះគាត់ខឹង
គាត់ថាលែងអោយដឹងលឺព្រោះចិត្តខ្មៅសំលាប់ប្ដីគាត់ណា
ត្រូវជាសាច់ញ្ញាតិដល់ពេលខ្ញុំវិញក៏មិនសូវបានដឹងពីប្រវិត្តគាត់នៅរដ្ឋណាអីណាអត់ដឹងទេ
។

កៈ ចាតែដឹងថាគាត់នៅស្រុកក្រៅ?

ខៈ ចាដឹងថាគាត់នៅស្រុកក្រៅ គាត់មកជញ្ជូនកូនចៅម្ដងមួយៗទៅ
ស្រុកកំណើតគាត់នៅព្រៃវែងណាស់។

កៈ ហើយសូមសួរអ៊ុំទៀតថា ស្វាមីរបស់អ៊ុំ តើគាត់មានឈ្មោះអីគេដែលអ៊ុំ?

ខៈ គាត់ឈ្មោះអើ មួងសារី ប៉ុន្តែរគាត់ស្លាប់ហើយអូន។

កៈ ឈ្មោះម៉ូងសារី។

ខៈ ចាហៅ លឹមច្រៀង។

កៈ អរគុណអ៊ុំ ចឹងអ៊ុំរៀបអាពាហ៍ពិពាហ៍នៅពេលណាដែលអ៊ុំ? ឆ្នាំណាខែណា?

ខៈ អ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់អើ ចេញពីសម័យប៉ុលពតមក
អត់មានបាននេះទេកូនបានតែមានលោកមួយអង្គរនៅភ្នំក្រោម
ហើយនិងតាអាចារ្យមួយនាក់និង រួចហើយម៉ែខ្ញុំក៏គាត់ថាកូនអើយ
កូន.ឯងក៏គ្រាន់បើដែលវាមិនមែនចាប់ដៃរសួចសម័យប៉ុលពតទេណាស់ សុទ្ធតែសាម
សែសិបគូ ដល់ពេលនេះទៅក៏ម្តាយខ្ញុំរៀបជាមួយប្តីខ្ញុំទៅ ចា។

កៈ ហើយអើការរៀបការអាពាហ៍ពិពាហ៍របស់អ៊ុំនិង គឺយល់ស្របតាមម្តាយរបស់អ៊ុំមែន?

ខៈ ចា ម្តាយខ្ញុំ។

កៈ ចារួចចុះអ៊ុំមានបង្កាប់ថ្លៃជំនួនពីខាងអ៊ុំប្រុសទេអ៊ុំ?

ខៈ អ៊ុំប្រុសនិងគាត់ អើម្តាយខ្ញុំគាត់ដូចថា
គាត់គ្រាន់តែថាអោយទិញរបស់របយកមករៀបចំ ព្រោះគាត់និងក៏អត់ដែលនិងណា
ហើយកាលនិងគេនៅចាយមាសនៅឡើយនិងអូន ចាអត់ទាន់មានលុយចាយទេ
ដល់រៀបចំខ្ញុំរួចបានពីរបីរខែហើយបានមានលុយ ព្រោះគាត់ធ្វើការនៅគមនីគម៏
នៅខេត្តបាត់ដំបងនិងណា។

កៈ អ៊ុំប្រុសធ្វើការអីដែលអ៊ុំកាលនិង?

ខៈ ចាគាត់ធ្វើការនៅគមនីគម៏ គាត់អើខាប្រធានផែនការណ៏ ចា។

កៈ ចាអរគុណអ៊ុំ ចង់សួរអ៊ុំថែមទៀតថា
នៅពេលអ៊ុំជួបអ៊ុំប្រុសដំបូងណាស់នៅពេលណាដែលអ៊ុំ?

ខៈ ជួបតាំងពីឆ្នាំ៧៩ហើយនិងអូន។

កៈ ចាពេលជួបនិងស្រលាញ់គ្នាតែម្តង ឬក៏យ៉ាងណាដែលអ៊ុំ?

ខៈ គឺម្តាយខ្ញុំគាត់ឃើញ ដូចថាគាត់រាប់អានតាមរយៈ
ដូចថាញាត្តិសណ្តានស្គាល់ប្តីខ្ញុំអីចរឹកគាត់យ៉ាងមេចៗអីចឹងណា
ក៏គាត់មកនិយាយប្រាប់ម្តាយខ្ញុំទៅ ចារ រួចក៏គាត់ព្រមថាកូនអើយ
កូន.ឯងចាស់ៗអស់ហើយ ហើយមិនមែនតែខ្ញុំណា បងស្រីខ្ញុំក៏អត់មានគ្រួសារដែល
ដល់ចឹងទៅដូចថាគាត់រៀបខ្ញុំហើយបានបងស្រីខ្ញុំគាត់រៀបអោយតាមក្រោយតាស់ ចារ។

កៈ ចាអរគុណអ៊ុំ ហើយចឹងខ្ញុំចង់សួរអ៊ុំថាសព្វថ្ងៃនិងអ៊ុំស្រលាញ់អ៊ុំប្រុសទេ?

ខៈ ស្រាលាញ់ ប៉ុន្តែរគាត់ស្លាប់បាត់ហើយ។

កៈ អរអ៊ុំប្រុសស្លាប់ហើយ។

ខៈ ចាខ្ញុំខំរត់រកលុយកាកធ្វើបុណ្យទានអោយគាត់ កុំអោយគាត់វេទនាដូចជាតិនេះ
គាត់ក៏លំបាកខ្ញុំក៏លំបាកដែលយើងជួបសម័យប៉ុលពតនេះណាស់ចារ។

កៈ ហើយគាត់ស្លាប់នៅពេលណាដែលអ៊ុំ?

ខៈ គាត់ស្លាប់នៅឆ្នាំមួយពាន់ប៉ុនន្មានទេ ដូចជាមួយពាន់
អាកាត់ប៉ា.ឯស្លាប់មួយពាន់ប៉ុនន្មាន?

គ.	១២ឆ្នាំមុន។

ខៈ ១២ឆ្នាំហើយនិងណា។

កៈ ចារ១២ឆ្នាំមុនដក ២០១៨។

ខៈ ២០១៦អីប៉ាស្លាប់?

គ.	ស្លាប់នៅឆ្នាខ្ញុំនេះ.ឯងឆ្នាំរកា អាឡូវឆ្នាំនេះឆ្នាំរការ ចឹងមិន១២ឆ្នាំមុន។

ខៈ មិនដឹងទេចឹងភ្លេចអស់ហើយ បើកូនខ្ញុំអាបងបាននៅចាំ។

កៈ គាត់ស្លាប់នៅឆ្នាំពីរពាន់អើ។

គ.	អាឡូវនិងពីរពាន់ដប់ប្រាំបីរ ដកទៅវាឆ្នាំ២០០៦។

ខ៖ និងហើយ២០០៦ចឹងណា។

ក៖ ចាអរគុណអ៊ុំ ហើយខ្ញុំសួរអ៊ុំទៀតថាអ៊ុំចេះសរសេរ ចេះអានហើយនិងចេះនិយាយភាសារខ្មែរច្បាស់ទេអ៊ុំ?

ខ៖ អ៊ុំចេះសរសេរបានតិចតួចនិងកូន មិនជាអ្នកពូកែសរសេរអីទេ ហើយអានបានតិចដែលនិង។

ក៖ ចាហើយអ៊ុំធ្លាប់រៀនពីមុនមកទេ?

ខ៖ អ៊ុំរៀនដែល ប៉ុន្តែរៀនបានតិចៗនៅផ្ទះមើលប្អូន រួចម៉ែថាកូនអើយឈប់ទៅ ទៅដេញចាបចឹងណាគ្មានបានរៀនប៉ុន្មានទេកូនអើយ ហើយចូលមកសម័យចឹងទៀតគ្មានបានរៀនអីទេអូនចា។

ក៖ ចឹងសូមសួរអ៊ុំថា អ៊ុំមានមិត្តភ័ក្តិជិតស្និតដែលធំឡើងជាមួយគ្នាទេអ៊ុំ?

ខ៖ មានប៉ុនន្តែរអាឡូវគេស្លាប់អស់ហើយនៅតែខ្ញុំ ហាហារ។

ក៖ ចឹងពួកគាត់មានឈ្មោះអីគេខ្លះដែលអ៊ុំ?

ខ៖ ពួកគាត់អើ នៅ.ឯស្រុកនិងគាត់ឈ្មោះអិម គាត់ឈ្មោះសុទ្ធ ចានិងកូនស្រីៗនិង ហើយដល់អាឡូវគេស្លាប់អស់រលីងហើយអូន បាត់តាំងពីរសម័យប៉ុលពតនោះ ឈ្មោះសុទ្ធនិងបាត់អស់ហើយ និងអ្នកនៅជាប់ផ្ទះគ្មានិងអត់ ដូចជាអ៊ុំអត់សូវមានពួកម៉ាក់មិត្តភ័ក្តិអីទេ ចាមានដូចថាស្រីៗអាយុប៉ុនគ្នាប្រហាក់ប្រហែលគ្នាដូចថារាប់អានចឹងណា ចាអត់សូវមានអ្នកជិតស្និតប៉ុនន្មានទេ។

ក៖ ចឹងខ្ញុំចង់សួរអ៊ុំទៀតថា តើអ៊ុំធ្លាប់ធ្វើការនៅវាលស្រែទេអ៊ុំ?

ខ៖ អ៊ុំទៅច្រូតទៅអីនៅ.ឯវាលស្រែជួយដាក់ទឹកដាក់អីឪពុកម្តាយដែលនិងណា។

ក៖ ចាហើយចុះចំការមានទេអ៊ុំ?

ខ៖ ចំការមានសណ្តែតចឹងទៅ អ៊ុំទៅបេះសណ្តែក។

ក៖ ចាហើយអ៊ុំជួយធ្វើអីខ្លះនៅក្នុងចំការដូចជាច្រូតស្រូវអីធ្លាប់ដែលអ៊ុំ?

ខ៖ ច្រូតស្រូវ ប្រជាន់ស្រូវ។

ក៖ ស្តាប់មើលទៅសប្បាយណាអ៊ុំ?

ខ៖ ហាហារ សប្បាយអីទៅច្រូតស្រូវនិងរមាស់ចង់ងាប់ ទៅបេះសណ្តែក
ហាហារអូនមិនដឹងចេះតែថាសប្បាយហើយ តែអត់សប្បាយទេ
បេះសណ្តែកអីចឹងទៅដែរយើងនិងវាពេលរមាស់ មិនដូចយើងអាឡូវគេមានស្រោមដៃ
ស្រោមអីពាក់និងវាអត់ដឹងគ្មានស្រោមដៃអីពាក់ទេ
ដល់សម័យអាឡូវគេពាក់ស្រោមដៃអីចឹងទៅ។

ក៖ ចាអរគុណអ៊ុំ ចឹងបន្ទាប់ពីធ្វើស្រែចំការ
តើអ៊ុំធ្លាប់ប្រកបរបរអាជីវកម្មអីផ្សេងៗទៀតអត់អ៊ុំ?

ខ៖ មិនដែលបានប្រកបអីទេអូន
ដល់តែមកសម័យនេះរកស៊ីមិនដឹងធ្វើអីមានតែលក់លៀសនិងគេទៅព្រោះអីយើងអត់មាន
ដើមទន់
ចាលក់សៀលនិងដូចថាយើងយកពីគេទៅលក់ចឹងទៅពេលមកវិញបានយើងអោយដើម
គេនិង ពួកនិងចឹងទាំងអស់គ្នានិង។

ក៖ ចាអរគុណអ៊ុំ។
ហើយចង់សួរអ៊ុំថាពីមុនរហូតមកដល់អាឡូវតើអ៊ុំបានឃើញថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរ
អីគេខ្លះដែលទេអ៊ុំ?

ខ៖ ពីមុនអូនអើយអ៊ុំលំបាកតែរឿង នោះគេថារត់ទៅនេះរត់ទៅនុះខ្លាច
រវល់ថាវាចេះតែមានសង្គ្រាមណាស់
ចាបើសិនជាសម័យយើងអាឡូវទោះបីអត់ឃ្លានក្រមានអីអត់សូវខ្វល់ទេព្រោះយើងចេះតែរ
កទៅវាបានហូបហើយចឹងណាកូន ចាខំប្រឹងទៅវាមានហើយ
វាអត់មានពីបាកអារឿងសង្គ្រាមអីទេណាកូន
ចឹងបានថាអ៊ុំអោយតែបានស្រុកទេសកុំអោយមានសង្គ្រាមអ៊ុំអរណា
អ៊ុំខ្លាចណាស់សង្គ្រាមព្រោះវាអាយុអ៊ុំមកមានសម័យ លុននល់ សម័យប៉ុលពត
ដល់ចឹងវាលំបាកមែនទែនខ្លាច លឺតែសង្គ្រាមសុំខ្លាចម៉ង។

ក៖ ចាខ្ញុំសូមសួរអ៊ុំទៀតថា តើមានម្ហូបអីគេខ្លះដែលអ៊ុំចូលចិត្តជាងគេ? អ៊ុំចូលចិត្តញាំណា?

ខ៖ អ៊ុំម្ហូបខ្មែរយើងចូលចិត្តទាំងអស់ ហាហារ។

ក៖ តែម្ហូបដែលអ៊ុំគិតថាឆ្ងាញ់ ហើយអ៊ុំចូលចិត្តញ៉ាំជាងគេ?

ខ៖ មានតែសំលរម្ជូរ សំលរកកូអីនិង ហាហារ សំលរប្រហើរ។

ក៖
ហើយអ៊ុំតើមានល្បែងកំសាន្តអីគេខ្លះដែលអ៊ុំចូលចិត្តលេងតាំងតែពីតូចរហូតមកដល់ពេលនិងណា ដូចបោះអង្គុញ ចោលឈូកអីនិង?

ខ៖
អ៊ុំចូលចិត្តទៅមើលដូចថាខែចូលឆ្នាំអីនិងដូចថាគេបោះអង្គុញអីលេងក្មេងស្រីៗក្រមុំៗអីណា ទៅលេងនិងគេទៅ ជួនកាលគេលេងចាប់កូនខ្លែងអ៊ុំទៅលេងនិងគេដែលនិងចារកាលនិងយើងនៅក្មេង។

ក៖ ហើយអ៊ុំចេះច្រៀងចំរៀងទេ?

ខ៖ អត់ផងអូន អ៊ុំអត់ចេះ។

ក៖ តែអ៊ុំចេះស្តាប់និងចូលចិត្តចំរៀងទេ?

ខ.អ៊ុំចូលចិត្តខ្លះដែលអូន។

ក៖ ភាគច្រើនអ៊ុំស្តាប់បទរបស់ពីណាគេដែលអ៊ុំ?

ខ៖ ភាគច្រើនបទអើ សម័យពីមុនណាអូន បទដូចថា លោកស៊ិនស៊ីសាកមុត ប៉ែនរ៉ុន ហើយនិងលោកហ៊ុយមាសអីនិងណាអូនចាខ្ញុំចូលចិត្តស្តាប់។

ក៖
ហើយខ្ញុំសូមសួរថាតើមាននរណាខ្លះនៅក្នុងក្រុមគ្រួសារអ៊ុំដែលគាត់ចេះលេងឧបរកណ៍ភ្លេងខ្មែរឬក៏ភ្លេងសម័យអីមានទេអ៊ុំ?

ខ៖ អើយបើប្អូនខ្ញុំដែលស្លាប់ទៅ វាទៅធ្វើទាហាននិងវាចេះច្រៀងអាយ៉ៃ ចារវាចេះច្រៀងអាយ៉ៃ ចេះកប្លែងចេះអីកាលនិងបានទៅកំប្លែងនៅខេត្តបាត់ដំបងនិងអូនគាត់ទៅកំប្លែងដល់ពេលគេអោយទៅធ្វើទាហានកាលនុះទៅគុតតាក្រែចំរៀងនោះក៏ជាន់មិ

នស្លាប់រហូតដល់សព្វថ្ងៃនិងអត់មានបានឃើញសាកសព្វទេ ស្លាប់ចោលម្ដាយ ចោលបងប្អូន។

កៈ ចាអរគុណអ៊ុំ ខ្ញុំសូមសួរអ៊ុំទៀតថា តើផ្ទះរបស់អ៊ុំតាំងពីក្មេងរហូតមកដល់អាឡូវផ្ទះដែលអ៊ុំរស់នៅនិងមានលក្ខណៈយ៉ាងមេច ដែលអ៊ុំផ្ទះណា?

ខៈ ផ្ទះខ្ញុំធ្វើខ្លួន.ឯងឬក៏?

កៈ ដូចជាផ្ទះឈើ អ៊ុំផ្លាស់ប្ដូរទៅនៅផ្ទះថ្មរ រក៏ផ្លាស់ប្ដូការជុសជួលអីណា មេចដែលអ៊ុំ?

ខៈ ចារអាឡូវអ៊ុំ កាលពីប្ដីខ្ញុំធ្វើការនិង គាត់ធ្វើការរដ្ឋចឹងគេអោយផ្ទះមួយល្វែងណាកូនណា ដល់អាឡូវអ៊ុំនៅខាងលើគេអ៊ុំនៅអត់កើតទេ គេនៅខាងក្រោមដូចថាគេចង្អៀតចង្អល់ គេមិនចង់អោយយើងចុះដល់ចឹងទៅអ៊ុំក៏លក់ផ្ទះនិងទៅ ដល់រួចមកលក់និងមិនបានថ្លៃទេកូនអើយ ធម្មតាយើងផ្ទះនៅលើណាកូនបានតែប៉ុនន្នានទេ ប្រាំបីរពាន់ ប្រាំបីរពាន់និងទៅធ្វើផ្ទះទៀតបានដូចថាគ្រាន់តែរៀបឥតធម្មតានិងដូចថាយើងខ្លាចខ្យល់ ហើយផ្ទះតៀមនិង។

កៈ ចាពេលអ៊ុំធ្វើផ្ទះនិងធ្វើខ្លួន.ឯងឬក៏អ៊ុំជួលជាងគេធ្វើអោយ?

ខៈ ប្អូនខ្ញុំជួលជាងហើយគេជួយធ្វើ។

កៈ ចាហើយអ៊ុំមានជួយធ្វើគេទេ?

ខៈ ហាហារ អ៊ុំជួយដាំបាយអោយគេហូប។

កៈ ហើយចុះក្នុងចំនោមកូនចៅអ៊ុំតើមាននរណាម្នាក់ដែលគាត់ចេះធ្វើផ្ទះដោយខ្លួន.ឯងទេអ៊ុំ?

ខៈ អត់មាននរណាទាន់មានផ្ទះផងនិងអូន។

កៈ ដូចជាចេះជួសជុលផ្ទះសាងសង់ផ្ទះអីអត់មានទេអ៊ុំ?

ខៈ អត់ទេ អត់ចេះទេ តែចេះតែបើកឡាន។

កៈ ចាបងប្រុសនិងមែនអ៊ុំ?

ខ៖ ចាកូនខ្ញុំបួននាក់និងចេះទាំងអស់គ្នាបើកឡាន អត់មានបានរៀនអីប៉ុនន្មានទេកូនអើយ
ព្រោះម្ដាយអត់ដែលហើយរស់តែឪពុកចឹងទៅឈឺចឹងទៅក៏
អាកូនខ្ញុំមួយនោះកាលមុនវាធ្វើការនៅពេទ្យម៉ាស្ទើរណា
ដល់ពេលឃើញប៉ាស្លាប់ចឹងទៅវាឈប់ ឈប់ទល់អាឡូវ
តែអាឡូវអត់មានការងារអីធ្វើលំបាកដែលនិង។

ក៖ ចាអរគុណអ៊ុំ ចឹងខ្ញុំសូមសួរអ៊ុំទៀតថាអើ
តើមានជំនាញអ្វើខ្លះដែលជីដូនជីតាអ៊ុំបានបន្សល់ទុកអោយអ៊ុំដូចជាការកូរស្ករ វិញវិល្ល
ត្បាញក្រមារឬក៏ធ្វើអីមានទេអ៊ុំ?

ខ៖ ពីឪពុកម្ដាយដូចជាគាត់អត់មានបង្រៀនអីយើងទេ
ព្រោះសម័យនិងវារស់តែរត់លូននិងកូន ហើយកាលពីមិនទាន់រត់លូននិងនៅស្ទើដែល
គាត់ប្រើអោយទៅចាំចាបចឹងទៅណា អោយទៅបេះសណ្ដែកអី
ច្រូតស្រូវច្រូតអីនិងគាត់មិនចង់អោយធ្វើទេខ្លាចមត់ដៃផង ដល់មកសម័យយើងនិង
ខ្ញុំមានប្ដីនិងក៏យើងចេះរកស៊ីលក់ដូរកំប៉ិកំប៉ុកដូចលៀសដូចអីចឹងទៅកូន
មានបន្លែបន្លុកអីនិង មិនដែលរកអីទេចា។

ក៖ អរគុណអ៊ុំ តើអ៊ុំធ្លាប់លំបាកនៅពេលណាខ្លះ
អ៊ុំអាចប្រាប់អំពីពេលលំបាកបំផុតនៅក្នុងជីវិតបានទេអ៊ុំ?

ខ៖ ពិបាកដែលនិងកូនអើយ កាលកូននៅតូចៗដូចថាប្ដីធ្វើការបានប្រាក់ខែតិចតួច
គ្រាន់តែគាត់ហូបតែមាត់គាត់និងមិនចង់គ្រប់ផង
ហើយដល់ចឹងទៅអ៊ុំមិនដែលចេះលក់ដូរអីទេតាំងតែពីដើមមក
ដល់តែនេះចេះតែរៀនលក់ដូរហូតបានមកលក់លៀសនិង
ហើយអាឡូវនិងក្រៅពីលៀសនិងមិនដឹងចេះលក់អីទៀតដូចថាយើងវាមិនធ្លាប់ណា
ហើយអាឡូវនិងវាកាន់តែវៃចំណាស់ប៉ុនខ្ញុំហើយនិង ខ្ញុំចង់ឈប់ដែលតែយើងវានៅ
កាលធ្វើផ្ទះនិងនៅខ្វះគេជំពាក់គេបួនប្រាំពាន់ទៀតណាកូន
ដល់ចឹងទៅនៅកូនហើយនិងខ្លួន.ឯងនិងចេះតែខំប្រឹងទៅរកដោះសង់គេ
ជំពាក់អេស៊ីលីដានិង។

ក៖ ចាខ្ញុំសួរអ៊ុំទៀតថា តើអ៊ុំឆ្លងកាត់ភាពពិបាកៗពីមុនមកនិងដោយរបៀបណាដែលអ៊ុំ?

ខ៖ ពីមុនៗមកនៅជាមួយឪពុកម្ដាយដូចជាអត់មានពិបាកអីទេ លើគាត់ទាំងអស់ ដល់តែមកខ្លួន.ឯងមានប្ដីមានកូនទៅបានដឹងពិបាក ពិបាកនិងអត់ឃ្លាននិងណាកូន បើយើងមិនប្រឹងទៅវាអត់ជូនកាលអត់មែនទែន ដល់ថ្នាក់សុំបង បងស្រីខ្ញុំសុំលុយគាត់ខ្លះទិញអង្ករយកមកអោយកូនហូប ដល់តែបងស្រីគាត់អត់មានកូន គាត់ចេះតែផ្ដល់អោយ ហើយគាត់ចាស់ហើយគាត់មានទៅសំបូរអីប៉ុន្មានគាត់ចេះតែផ្ដល់ទៅ រួចខ្ញុំក៏ចេះតែខំប្រឹងរកទៅ ចេះតែបានត្រដេរ ត្រដរមកលក់លៀសនិងកុំអីនិងមិនបានចិញ្ចឹមកូនរស់ទេ តាំងពីនិងមកអ៊ុំលក់ឡើង២០ឆ្នាំហើយណាកូនលៀសនិងណា។ ចឹងបានថាលៀសនិងក៏មានគុណលើគ្រួសារខ្ញុំណាស់ដែល បើសិនជាមិនមានលៀសលក់និងខ្ញុំច្បាស់ជាលំបាកណាស់មិនដឹងទៅរកអីព្រោះយើងអត់មានដើមណា។

ខ៖ ចាអរគុណអ៊ុំ។ ចឹងទាក់ទងនិងបទពិសោធ៍ល្អៗនៅក្នុងជីវិតរបស់អ៊ុំវិញ តើអ៊ុំមានអ្វីខ្លះដែលធ្វើអោយជីវិតរបស់អ៊ុំរីករាយនិងសប្បាយបំផុតនៅក្នុងជីវិតតើពេលណាដែលអ៊ុំ?

ខ៖ អាឡូវនេះដូចថាអ៊ុំ មួយជីវិតខ្ញុំនេះដូចថារកសប្បាយមិនឃើញ ប៉ុន្តែដល់ពេលដែលកូនមានប្រពន្ធមានចៅអីចឹងទៅ វាចេះតែមកយាយចេះ យាយចុះចឹងទៅ ដូចថាធ្វើអោយយើងរសាយលំបាកនិង។ ខ្ញុំធ្លាប់លំបាកពេក ធ្វើអោយខ្ញុំមានជំងឺស្រើត ហើយអាឡូវខ្ញុំខ្សោយបេះដូងណាស់មីអូនអើយ លើសឈាមទៀត ប៉ុន្តែខ្ញុំចេះតែទ្រាំ ធ្វើមេចជីវិតយើងវាអត់។

ក៖ ចាចឹងងស់ហើយ ខ្ញុំសូមសួរអ៊ុំថាកាលនៅពីក្មេងរហូតដល់ធំចំណាស់នេះតើអ៊ុំធ្លាប់សង្ឃឹមចង់បានអីនៅក្នុងជីវិតរបស់អ៊ុំពេលដែលអ៊ុំធំឡើងណា ធ្លាប់មានដែលអត់អ៊ុំ?

ខ៖ អ៊ុំចង់បានចង់មានដែលប៉ុន្តែវារកទៅដូចថាវាមិនជួបដូចគេណាកូន ដូចថាយើងរកគ្រាន់តែមួយរស់ៗចារដល់ទៅមានគ្រួសារហើយគាត់ធ្វើការនិងក៏ប្រាក់ខែវាតិចតួច គាត់អត់មានបានដូចថា មានកំរៃនិងបានធំច្រើនអី មិនដឹងទៅរកអីធំនិងគេទេ ចេះតែរកតក់ៗនិងខ្ញុំធ្វើនំធ្វើអីលក់ខ្លះទៅ ទទួលនំគេលក់ខ្លះទៅ ចេះអោយតែបានកូនហូបទៅអោយតែបានរស់រៀនមានជីវិតដល់មកថ្ងៃនេះទៅ

អាឡូវនិងក៏វាគ្មានស្អីចែកកូនចែកចៅដែល
គ្រាន់តែថាបានអោយវារស់ទៅរួចហើយវារកអីរកទៅ
ខ្ញុំចាស់ហើយអាយុហុកជាងហើយក៏ចេះតែខំទៅ
អ្នកខ្លះអាយុហុកជាងហើយដើរមិនរួចផងនិងចេះតែខំតស៊ូស្រវេស្រវាទៅ
រាល់ថ្ងៃបានតែកូនខ្ញុំនិងមួយនិងរៀងធូតិច ដូចថាប្រពន្ធគេ
គេចេះលក់ដូអីចឹងទៅគេចេះជួយបងប្អូនខ្លះទៅណា។

កៈ ចាអេគុណអ៊ុំ។ ចឹងខ្ញុំសូមសួរអ៊ុំនៅសំនួរចុងក្រោយ
ចង់សួរអ៊ុំថាតើអ៊ុំអាចផ្តាំផ្ញើរអ្វីខ្លះទៅកាន់កូនចៅអ៊ុំនៅជំនាន់ក្រោយៗ
អ៊ុំនិយាយអ្វីខ្លះទៅកាន់ពួកគាត់ណាអ៊ុំ?

ខៈ ផ្តាំកូនជំនន់ក្រោយ អោយកូនខំរៀន អោយបានធ្វើការងារកុំអោយលំបាកដូចអ៊ុំ
គ្មានចំណេះវិជ្ជាអីអ៊ុំលក់ដូរលំបាកណាស់ ហើយខំប្រឹងរៀនសូត្រអោយបានធ្វើការងារ
ជៀសវាងកុំជក់គ្រឿងញៀន ខុះរៀនខំសូត្រដើម្បីអោយមានតំរិះវិជ្ជាធ្វើការងារអ្វី
ដូចជាគ្រូបង្រៀន ដូចជាគ្រូពេទ្យ ឬក៏ណែកអោយបានធ្វើដកទ័រអីទៅ ចារ។

កៈ ចាអរគុណអ៊ុំ ចាចឹងជាចុងក្រោយ អ៊ុំអស់ហើយងត់មានអីទៀតទេ?

ខៈ ចាអស់ហើយ។

កៈ
ចារចឹងបើងស់ហើយខ្ញុំសូមអរគុណច្រើនសំរាប់ឪកាសដែលអ៊ុំអនុញ្ញាតអោយខ្ញុំបានសំភាស៍អ៊ុំ។
ហើយសំរាប់ជីវប្រវិត្តរបស់អ៊ុំពួកយើងនិងយកទៅដាក់នៅក្នុងអើប្រព័ន្ធវើបសាយរបស់សាលា BYU ណាអ៊ុំ អរគុណអ៊ុំច្រើន។